# មាតិកា


**១- សេចក្តីផ្តើម**

**២- គោលបំណង**

**៣- តួនាទីសារមន្ទីរក្នុងតំបន់បេតកភណ្ឌ**

**៤- ប្រវត្តិនៃដំណើរការរៀបចំសារមន្ទីរ**

*៤-១. គំនិតផ្តួចផ្តើម*

*៤-២. ការងារសាងសង់*

*៤-៣. ការងារពិព័រណ៍*

**៥- សមិទ្ធផល**

*៥-១. អគារបារមីលោកតាឪ*

*៥-២. អគារពិព័រណ៍អចិន្ត្រៃយ៍*

*៥-៣. អគារពិព័រណ៍មិនអចិន្ត្រៃយ៍*

*៥-៤. អគារសោតទស្សន៍*

*៥-៥. អគារបដិសណ្ឋារកិច្ច និងការិយាល័យ*

*៥-៦. អគារពេងដាង និងឃ្លាំង*

**៦- សកម្មភាពការងារ**

*៦-១. ការចុះបញ្ជីសារពើភណ្ឌ*

*៦-២. ការអភិរក្សសមុច្ច័យ*

*៦-៣. ការប្រមូលវត្ថុសិល្បៈ*

*៦-៤. ការអប់រំផ្សព្វផ្សាយ*

**៧- ទស្សនៈវិស័យរបស់សារមន្ទីរ**

## ១-សេចក្ដីផ្ដើម

ខេត្តព្រះវិហារ ស្ថិតក្នុងភូមិសាស្ត្រឧត្តរនៃព្រះរាជាណាចក្រកម្ពុជា នៅឆ្ងាយពីរាជធានីភ្នំពេញ ៣២០ គ.ម ជាខេត្តស្ថិតនៅតំបន់ខ្ពង់រាប តំបន់ព្រៃភ្នំ ភូមិសាស្ត្រមានភាពទូលាយ សំបូរព្រៃឈើធំៗជាជំរកសត្វព្រៃគ្រប់ប្រភេទ ធនធានធម្មជាតិ រ៉ែ និងសំណង់ប្រវត្តិសាស្ត្រ ប្រាសាទបុរាណ មានច្រើនឥតគណនា។

អ្នកសិក្សាស្រាវជ្រាវខាងបុរាណវិទ្យា របស់សាលាបារាំងចុងបូព៌ា បានចងក្រងឯកសារ **«បញ្ជីសារពើភណ្ឌស្ថានីយបុរាណប្រទេសកម្ពុជា ខេត្តព្រះវិហារ»** ជាព័ត៌មានទាក់ទងនឹងទិន្នន័យស្ដីពីសំណង់ប្រវត្តិសាស្ត្រ និងប្រាសាទបុរាណ។ តាមរយៈឯកសារនេះ យើងបានដឹងថា នៅស្រុកជាំក្សាន្តមួយ មានសំណង់ប្រវត្តិសាស្ត្រ និងប្រាសាទបុរាណ ចំនួន៨៣ ក្នុងនោះ ឃុំកន្ទួតមានប្រាសាទចំនួន១១ ឃុំជាំក្សាន្ត មានប្រាសាទចំនួន០៧ ឃុំទឹកក្រហម មានប្រាសាទចំនួន១៨ ឃុំព្រីងធំ មានប្រាសាទចំនួន២២ ឃុំរំដោះស្រែ មានប្រាសាទចំនួន១៣ និងឃុំយាង មានប្រាសាទចំនួន១២។ អ្វីដែលគួរឱ្យបារម្ភនោះ គឺទីតាំងប្រាសាទនៅមានគ្រាប់មីន និងគ្រាប់មិនទាន់ផ្ទុះជាច្រើន វត្ថុសិល្បៈ នៅរាយប៉ាយក្នុងបរិវេណប្រាសាទនានា គ្មានការថែទាំ ងាយនឹងបាត់បង់ដោយជនទុច្ចរិត។ ចំណែកឯប្រជាជននៅក្នុងតំបន់ ដែលមិនបានយល់អំពីតម្លៃនៃសំណង់ប្រវត្តិសាស្ត្រ និងប្រាសាទបុរាណ ក៏បាននាំគ្នារុករានទន្ទ្រានយកដីយ៉ាងអានាធិបតេយ្យ ធ្វើឱ្យមានការប៉ះពាល់ជាអវិជ្ជមាន និងធ្វើឱ្យប្រាសាទទាំងនោះរងការខូចខាតកាន់តែធ្ងន់ធ្ងរ។

មួយវិញទៀត អន្ដោគ្រាម «កួយ» ជាជនជាតិមួយដែលធ្លាប់មានវប្បធម៌ ប្រពៃណី ទំនៀមទម្លាប់ និងអត្តសញ្ញាណរបស់ខ្លួន តាំងពីយូរលង់មក។ សម្រាប់ពេលបច្ចុប្បន្ន វប្បធម៌ ប្រពៃណី ទំនៀមទម្លាប់ និងអត្តសញ្ញាណរបស់ពួកគេ ប្រឈមទៅនឹងចរន្តសាកលភាវូបនីយកម្មសម័យទំនើប កាន់តែបាត់បង់បន្តិចម្ដងៗ តាមរយៈការខិតចូលមកសម័យទំនើប ហើយបានទទួលនូវវប្បធម៌ និងអរិយធម៌នៃជនជាតិខ្មែរ ដែលរស់នៅក្នុងតំបន់ជាមួយគ្នា។ ម្យ៉ាងទៀត ដោយសារមានការចូលរួមពីជនចំណូលថ្មីក៏ដូចជាការអភិវឌ្ឍនៅក្នុងដំបន់ដែលបងប្អូនជនជាតិកួយរស់នៅ សកម្មភាពនេះ ធ្វើឱ្យអត្តសញ្ញាណជនជាតិកួយ មានការថយចុះជាបណ្ដើរៗ។

ដោយហេតុថា យើងមិនត្រូវនិងមិនអាចទប់ស្កាត់ការអភិវឌ្ឍ នៅក្នុងតំបន់ដែលបងប្អូនជនជាតិកួយរស់នៅ ហើយក៏មិនចង់ឱ្យវប្បធម៌ ប្រពៃណី ទំនៀមទម្លាប់ អត្តសញ្ញាណ របស់បងប្អូនដែលមានតាំងពីយូរលង់មក ត្រូវបាត់បង់ ឬបំភ្លេចចោល និងមិនចង់ឱ្យមានការបាត់បង់សំណង់ប្រវត្តិសាស្ត្រ ប្រាសាទបុរាណ វត្ថុសិល្បៈដែលនៅរាយប៉ាយក្នុងបរិវេណប្រាសាទនានា ប្រភេទសត្វប្រភេទរុក្ខជាតិនៅក្នុងតំបន់ នោះការបង្កើតឱ្យមានសារមន្ទីរ គឺជាការចាំបាច់៕

## ២-គោលបំណង

រាជរដ្ឋាភិបាលកម្ពុជា បានស្នើសុំបញ្ចូលប្រាសាទព្រះវិហារទៅក្នុងបញ្ជីបេតិកភណ្ឌពិភពលោក របស់អង្គការយូណេស្កូ ក្នុងឆ្នាំ២០០១។ នៅថ្ងៃទី៧ ខែកក្កដា ឆ្នាំ២០០៨ គណៈកម្មការបេតិកភណ្ឌពិភពលោក បានប្រកាសជាឧឡារិកក្នុងសម័យប្រជុំលើកទី៣២ នៅទីក្រុងកេបិក ប្រទេសកាណាដា ដាក់បញ្ចូលប្រាសាទព្រះវិហារ ជារមណីយដ្ឋានទី២របស់ប្រទេសកម្ពុជា ទៅក្នុងបញ្ជីបេតិកភណ្ឌពិភពលោកបន្ទាប់ពីអង្គរដែលបានចូលក្នុងឆ្នាំ១៩៩២។

តាមរយៈកិច្ចគាំទ្រពីអង្គការយូណេស្កូ រាជរដ្ឋាភិបាលកម្ពុជា បានបង្កើតសារមន្ទីរធម្មជាតិសកល សម្ដេចតេជោ **ហ៊ុន សែន** ព្រះវិហារ នេះឡើងក្នុងគោលបំណង ថែរក្សា និងតាំងបង្ហាញនូវតម្លៃជាប្រវត្តិសាស្ត្រព្រមទាំងវប្បធម៌របស់រមណីយដ្ឋាន រួមទាំងប្រជាជន និងជនជាតិដើមភាគតិចកួយនៅក្នុងតំបន់ផងដែរ។

ម្យ៉ាងទៀត ជាទស្សនៈវិស័យរបស់រាជរដ្ឋាភិបាលកម្ពុជា ពិសេស**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** មិនចង់បានសង្គ្រាម ចង់បានសន្តិភាព ចង់ឃើញការអភិវឌ្ឍន៍ យកចិត្តទុកដាក់លើកស្ទួយជីវភាពរស់នៅរបស់ប្រជាជន និងយកចិត្តទុកដាក់លើការអភិរក្សកេរតំណែលប្រវត្តិសាស្ត្រ ដែលជាមរតកវប្បធម៌និងធម្មជាតិ មិនអាចកាត់ថ្លៃបានរបស់បុព្វបុរសខ្មែរ កុំឱ្យបាត់បង់ដោយប្រការផ្សេងៗ ដែលគួឱ្យអៀនខ្មាស និងសោកស្តាយជាទីបំផុត។ ប្រការនេះ បានបង្ហាញឱ្យឃើញតាមរយៈការបង្កើតឱ្យមានភូមិ មានសាលារៀន មានវត្តអារាម មានសារមន្ទីរ នៅតំបន់រមណីយដ្ឋានបេតិកភណ្ឌពិភពលោក ក្នុងដំណាក់កាលមានសង្គ្រាមជាមួយប្រទេសជិតខាង(ថៃ) ពីឆ្នាំ២០០៨ ដល់ឆ្នាំ២០១១ ៕

## ៣-តួនាទីសារមន្ទីរ ក្នុងតំបន់បេតកកភណ្ឌពិភពលោក

សារមន្ទីរធម្មជាតិ សកល សម្តេចតេជោ **ហ៊ុន សែន** ព្រះវិហារ ជាសារមន្ទីរបែបអេកូទេសចរណ៍តែមួយគត់របស់ប្រទេសកម្ពុជា មានផ្ទៃដី១៧៧ហិចតា ក្នុងនោះគ្របដណ្តប់ដោយព្រៃធម្មជាតិប្រមាណជា៨០%។

យើងទាំងអស់គ្នាជ្រាបហើយថា សារមន្ទីរគឺជាស្ថាប័នវប្បធម៌ចម្បងមួយ ដើរតួនាទីសំខាន់ក្នុងការផ្ទេរសម្បត្តិវប្បធម៌ និងធម្មជាតិដ៏មានតម្លៃគ្រប់ប្រភេទ។ ចាប់តាំងពីឆ្នាំ១៩៦០ ជាឆ្នាំដែលអង្គការយូណេស្កូអនុវត្តវិធានការណ៍អន្តរជាតិផ្តោតតែលើបញ្ហាសារមន្ទីរ យើងសង្កេតឃើញថា តួនាទីរបស់សារមន្ទីរបានប្រែប្រួល ពោលគឺអាចដើរតួនាទីជាអ្នកផ្សារភ្ជាប់សារជាណជនជាមួយសម្បត្តិបេតិកភណ្ឌ តាមរយៈការបង្កើតថ្មី ការអប់រំផ្សព្វផ្សាយគ្រប់បែបផែន ដើម្បីជំរុញការសន្ទនាអន្តរវប្បធម៌ និងការអភិវឌ្ឍន៍ប្រកបដោយចេរភាព។

ដោយឡែកសារមន្ទីរធម្មជាតិ សកល សម្តេចតេជោ **ហ៊ុន សែន** ព្រះវិហារ ជាសារមន្ទីរមួយនៅក្នុងតំបន់បេត្តិកភណ្ឌពិភពលោក បានដើរតួនាទីសំខាន់ៗ ដូចខាងក្រោម៖

-ជាមណ្ឌលសិក្សាស្រាវជ្រាវ អំពីបេតិកភណ្ឌរូបី បេតិកភណ្ឌអរូបី សត្វ និងរុក្ខជាតិ

-ជាមណ្ឌលអភិរក្សកេរតំណែលប្រវត្តិសាស្ត្រ ដែលជាមរតកវប្បធម៌ មិនអាចកាត់ថ្លៃបានរបស់បុព្វបុរសខ្មែរ

-ជាមណ្ឌលអប់រំ និងផ្សព្វផ្សាយ ។

## ៤- ប្រវត្តនៃដំណើរការរៀបចំសារមន្ទីរ

### *៤-១. គំនិតផ្តួចផ្តើម*

សារមន្ទីរធម្មជាតិ សកល សម្តេចតេជោ **ហ៊ុន សែន** ព្រះវិហារ ចាប់ផ្តើមកសាងនៅថ្ងៃទី១១ ខែឧសភា ឆ្នាំ២០០៨ តាមរបៀបស្ថាបត្យកម្មខ្មែរសុទ្ធសាធ ក្រោមគំនិតផ្តួចផ្តើមដ៏ខ្ពង់ខ្ពស់បំផុត **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុនសែន** និងដឹកនាំកសាងដោយ ឯកឧត្តមបណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងអនុវត្តការងារដោយកងវិស្វកម្ម ក្រុមការងារពិសេសថ្នាក់ជាតិតំបន់ប្រាសាទព្រះវិហារ។

ប្លង់រួមសារមន្ទីរធម្មជាតិសកល សម្តេចតេជោ ហ៊ុន សែន ព្រះវិហារ



### *៤-២. ការងារសាងសង់*

ក្រុមការងារសាងសង់ ដឹកនាំផ្ទាល់ដោយឯកឧត្តម **សួស យ៉ារ៉ា** អ្នកតំណាងរាស្ត្រមណ្ឌលខេត្តព្រះវិហារ និងជាអនុប្រធានប្រចាំការក្រុមការងារពិសេសថ្នាក់ជាតិតំបន់ប្រាសាទព្រះវិហារ បានចំណាយពេលវេលាជិត២ឆ្នាំ ហើយបានរំលេចឡើងនូវសមិទ្ធផលផ្សេងៗ ដូចខាងក្រោម៖


















### ៤-៣. ការតាំងពិព័រណ៍

ក្រោយពីកិច្ចការសាងសង់បានបញ្ចប់ ក្រុមការងារតាំងពិព័រណ៍របស់សារមន្ទីរបានចាប់ផ្តើមរៀបចំដោយមានការចូលរួមពីអ្នកជំនាញការបរទេសផង បានសម្រេចបែងចែកការតាំងពិព័រណ៍ជា៥ផ្នែកគឺ (១)ផ្នែកបុរាណវិទ្យា (២) ផ្នែកប្រវត្តិសាស្ត្រ (៣)ផ្នែកវប្បធម៌ជនជាតិភាគតិចកួយ (៤)ផ្នែកសត្វ និងរុក្ខជាតិ និង(៥)ផ្នែករូបថតសិល្បៈ។















**៥- សមិទ្ធផល**

សារមន្ទីរធម្មជាតិសកល សម្តេចតេជោ **ហ៊ុន សែន** ព្រះវិហារ មិនទាន់សម្ពោធដាក់ឱ្យទស្សនាជាសាធារណៈនៅឡើយ។ បច្ចុប្បន្នមានសមិទ្ធផលជាច្រើនបានតាំងបង្ហាញ ដែលវត្ថុទាំងនោះសុទ្ធតែបញ្ជាក់នូវតម្លៃប្រវត្តិសាស្ត្រ វប្បធម៌របស់រមណីយដ្ឋាន រួមទាំងសត្វ រុក្ខជាតិ ទំនៀមទម្លាប់ប្រពៃណីរបស់ជនជនជាតិដើមភាគតិចកួយផងដែរ។

*៥-១. អគារបារមីលោកតាឌី*



ជាទីសក្ការបូជាមួយ មានតម្កល់បដិមាមេទ័ពខ្លាំងពូកែម្នាក់ ឈ្មោះ តាឌី។ រឿងនេះមានប្រវត្តិទាក់ទងនឹងពើងភ្នំមួយនៅខាងត្បូងប្រាសាទព្រះវិហារ ហៅថាពើយតាឌី នៅទីនោះគេមានជំនឿថា មានព្រលឹងថែរក្សារបស់មេទ័ពដ៏ខ្លាំងពូកែម្នាក់នៃចក្រអង្គរសណ្ឋិតនៅ។

ជាទូទៅ ជនជាតិខ្មែរ ឱ្យតែមកដល់ប្រាសាទព្រះវិហារ គេតែងនឹកដល់បារមីលោកតាឌីជានិច្ច។

*៥-២. អគារពិព័រណ៌អចិន្ត្រៃយ៍*



អគារពិព័រណ៌អចិន្ត្រៃយ៍ មាន០២អគារ រាងជាអក្សរ(H) បានតាំងពិព័រណ៌ចែកជា៤ផ្នែកគឺ ផ្នែកបុរាណវិទ្យា ផ្នែកប្រវត្តិសាស្ត្រ ផ្នែកវប្បធម៌ជនជាតិភាគតិចកួយ និង ផ្នែកសត្វនិងរុក្ខជាតិ។

**-ពិព័រណ៍ផ្នែកបុរាណវិទ្យា**



ផ្នែកនេះ មានតាំងបង្ហាញនូវវត្ថុសិល្បៈអំពីថ្មភក់ដែលប្រមូលពីប្រាសាទនានា មានប្រវត្តិតាំងពីសម័យអង្គរចំនួន១៨ដុំ ។

**-ពិព័រណ៍ផ្នែកប្រវត្តិសាស្ត្រ**



ផ្នែកនេះ មានតាំងបង្ហាញនូវឯកសារប្រវត្តិសាស្ត្រ និងវត្ថុសិល្បៈដែលមានប្រវត្តទាក់ទងជាមួយតំបន់បេតិបេកណ្ឌពិភពលោក នៅប្រទេសកម្ពុជា ឡាវ និងវៀតណាម។

ពិព័រណ៍ផ្នែកនេះ បង្ហាញឱ្យឃើញពីលក្ខណៈពិសេសរបស់ប្រទេសនិមួយៗក្នុងប្រវត្តិសាស្ត្រពិភពលោក៕

**-ពិព័រណ៍ផ្នែក វប្បធម៌ជនជាតិភាគតិចគួយ**



ផ្នែកនេះ មានតាំងបង្ហាញអំពីភស្តុតាងនៃចំណេះដឹងផ្សេងៗ ក្នុងជីវភាពរស់នៅរបស់ជនជាតិភាគតិចគួយ ដូចជាៈ សម្ភារៈប្រើប្រាស់ រូបថត និងវីដេអូគ្លីប បង្ហាញអំពីជំនឿ ទំនៀមទម្លាប់ប្រពៃណី និងសកម្មភាពផ្សេងៗរបស់ពួកគេ។

**-ពិព័រណ៍ផ្នែក សត្វនិងរុក្ខជាតិ**



ផ្នែកនេះ មានតាំងបង្ហាញ សំណាក និងរូបថតប្រភេទសត្វកម្រ ប្រភេទរុក្ខជាតិ និងការប្រើប្រាសអនុផលព្រៃឈើក្នុងជីវភាពរស់នៅ។

## *៥-៣. អគារពិព័រណ៍មិនអចិន្ត្រៃយ៍*



អគារនេះ រាង៤ជ្រុង ដាក់តាំងបង្ហាញរូបថតសិល្បៈ ចែកជា២ផ្នែក។

ផ្នែកទី១ តាំងរូបថតសិល្បៈ ប្រាសាទព្រះវិហារ សម្រាប់ជាព័ត៌មានដល់ទេសចរ មុនពេលទស្សនាប្រាសាទ។

ផ្នែកទី២ តាំងរូបថតសិល្បៈបែបធម្មជាតិ បង្ហាញអំពីទេសភាពវប្បធម៌ និងធម្មជាតិ នៃបណ្ដាប្រាសាទនានាក្នុងតំបន់បេតិកភណ្ឌរបស់កម្ពុជា។







## *៥-៤. អគារសោតទស្សន៍*



ខ្សែវីដេអូជាទស្សនីយភាពចំនួន១០នាទី នៅក្នុងបន្ទប់នេះ នឹងបង្ហាញជូនអ្នកទស្សនា អំពីប្រវត្តិនៃការកសាងប្រាសាទព្រះវិហារ និងតួនាទីរបស់សារមន្ទីរក្នុងតំបន់បេតិកភណ្ឌ។

## *៥-៥. អគារបដិសណ្ឋារកិច្ច និងការិយាល័យ*



អគារនេះចែកចេញជាពីផ្នែក មួយផ្នែកសម្រាប់បដិសណ្ឋាកិច្ចភ្ញៀវ និងគណៈប្រតិភូដែលមកទស្សនាពិព័រណ៍សារមន្ទីរ មួយផ្នែកទៀតជាការិយាល័យធ្វើការសម្រាប់មន្ត្រីសារមន្ទីរ។

### *៥-៦. អគារពេងជាង និងឃ្លាំង*

អគារនេះ ប្រើប្រាស់ជាឃ្លាំង និងជាកន្លែងជួសជុលបុរាណវត្ថុ មុនយកទៅដាក់តាំង។



ទិដ្ឋភាពខាងក្រៅអគារ



ទិដ្ឋភាពខាងក្នុងអគារ

## **៦- សកម្មភាពការងារ**

សារមន្ទីរធម្មជាតិសកល សម្តេចតេជោ **ហ៊ុន សែន** ព្រះវិហារ ទោះជាពុំទាន់សម្ភោធឱ្យដំណើរការជាសាធារណៈក៏ដោយ ក៏សារមន្ទីរនេះបានធ្វើសកម្មភាពដែលជាតួនាទីរបស់ខ្លួនជាបន្តើរៗដូចជា៖

### *៦-១. ការចុះបញ្ជីសារពើភណ្ឌ*

មន្ត្រីជំនាញរបស់សារមន្ទីរធម្មជាតិសកល សម្តេចតេជោ **ហ៊ុន សែន** ព្រះវិហារ បានសហការជាមួយអ្នកជំនាញមកពីអង្គការយូណេស្កូ ផ្ទៀងផ្ទាត់បញ្ជីសារពើភណ្ឌ និងបន្តការចុះបញ្ជីសមុច្ច័យរបស់សារមន្ទីរ។





**ក្រុមការងារ ក្នុងសកម្មភាពផ្ទៀងផ្ទាត់បញ្ជីសារពើភណ្ឌ**

កែសម្រួលបញ្ជីសារពើភណ្ឌពីកម្មវិធី word ទៅកម្មវិធី database





Preah Vihear National Authority
Samdech Techo Hun Sen Eco-Global Museum of Preah Vihear

Item Certificate No. 21

| | | | |
|---|---|---|---|
| Responsible agency | Preah Vihear National Authority | | |
| Depository | Samdech Techo Hun Sen Eco-Global Museum of Preah Vihear | | |
| Address | Nationl Road #62, Eco-Village, Sra Em Commune, Choam Ksant District, Preah Vihear Province | | |
| Name | Iron piece | Number | PV1.2012. 21 |
| Material | Iron | Previous number | N/A |
| DSC06202.JPG | | | |
| Dimension (cm) | Height:/Width: 11.2/Length: 17 /Thickness: 5 /Diameter: 70 /Weight: 1.7 (kg) | | |
| Era | | Style | |
| Origin | Sanlong O Sa'ork work site, M'lou Prey Village, M'lou Prey Commune, Chhaep District, Preah Vihear Province | | |
| Discovered/given by | H. E. Thuy Chan Thuon ឯកឧត្តម ធុយ ចាន់ធួន | | |
| History of its discovery | Excavation | | |
| | | Date of discovery | 12 January 2010 |
| Reason of entry | For exhibition | Entry date | 8 September 2012 |
| Description and special mark | This iron piece, in grey color, was extracted from raw metal to use as a weapon or other purposes. | | |
| Condition | In good condition | | |
| Reference document | | | |
| Registration date | 13 February 2013 | Registered by | Samdech Techo Hun Sen Eco-Global Museum of Preah Vihear |




## ៦-២. *ការបណ្តុះបណ្តាល*

ក្នុងឆ្នាំ២០១៣ អាជ្ញាធរជាតិព្រះវិហារបានបើកវគ្គបណ្តុះបណ្តាលជំនាញអភិរក្សកុលលាភាជន៍រយៈពេល៣ខែ នៅសារមន្ទីរធម្មជាតិ សកល សម្តេចតេជោ ហ៊ុន សែន ព្រះវិហារ។









## ៦-៣. *ការប្រមូលវត្ថុសិល្បៈ*

វត្ថុសិល្បៈដែលនៅរាយប៉ាយតាមប្រាសាទនានា ខ្វះការថែទាំ ងាយនិងបាត់បង់ ត្រូវបានក្រុមការងាររបស់សារមន្ទីរធម្មជាតិ សកល សម្តេចតេជោ ហ៊ុន សែន ព្រះវិហារ ធ្វើការប្រមូលវត្ថុសិល្បៈទាំងនោះយកមករក្សាទុកនៅសារមន្ទីរ។










ក្រៅពីនេះ ក្រុមការងារក៏បានទទួលវត្ថុសិល្បៈពីប្រជាជន និងបណ្តាអង្គភាពនានា នៅក្នុងតំបន់រមណីដ្ឋាន។









### ៦-៤. *ការអភិរក្សសមុច្ច័យ*

វត្ថុសិល្បៈនានា ដែលប្រមូលបានពីប្រាសាទនានា ពីអង្គភាពនានា និងពីប្រជាជន ត្រូវបានក្រុមអ្នកជំនាញរបស់សារមន្ទីរធ្វើការសំអាត និងជួសជុលតាមលក្ខណៈបច្ចេកទេស មុនយកទៅដាក់តាំងឬយកទៅរក្សាទុកនៅទីតាំងសុវត្ថិភាព។









### ៦-៥. *ការអប់រំផ្សព្វផ្សាយ*

សារមន្ទីរធម្មជាតិសកល សម្តេចតេជោ ហ៊ុន សែន ព្រះវិហារ បានបង្កើតកម្មវិធីអប់រំផ្សព្វផ្សាយមួយ ស្តីពី **«សារប្រយោជន៍នៃចំណេះដឹងសារមន្ទីរក្នុងតំបន់បេតិកភណ្ឌ»** ដល់សិស្សានុសិស្ស និស្សិត ប្រជាជន មន្ត្រីរាជការ និងកងកម្លាំងប្រដាប់អាវុធ។

កម្មវិធីអប់រំផ្សព្វផ្សាយនេះ ធ្វើឡើងក្នុងបំណងបញ្ជ្រាបចំណេះដឹងទូទៅទាក់ទងនឹងអរិយធម៌ ប្រវត្តិសាស្រ្ត តម្លៃបេតិកភណ្ឌ និងបរិស្ថាន ដល់ពួកគេក្នុងនាមជាម្ចាស់បេតិកភណ្ឌ ដើម្បីបណ្តុះស្មារតី ស្រឡាញ់ ការពារ អភិរក្ស និងផ្សព្វផ្សាយបន្ត។





សិស្សានុសិស្ស មកពីសាលាបឋមសិក្សានិងអនុវិទ្យាល័យ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ស្រះក្តុល




និស្សិតមកពី សាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ




និស្សិតមកពី វិទ្យាស្ថានជំនាន់ថ្មី




និស្សិតមកពី សាកលវិទ្យាល័យអាស៊ី អឺរ៉ុប




និស្សិត នាយទាហានសកម្ម

**៧- ទស្សនៈវិស័យរបស់សារមន្ទីរ**

សារមន្ទីរធម្មជាតិសកល សម្តេចតេជោ ហ៊ុន សែន ព្រះវិហារ ជាសារមន្ទីរមួយនៅក្នុងតំបន់រមណីដ្ឋានបេតិកភណ្ឌពិភពលោក មានទស្សនៈវិស័យបង្ហាញឱ្យឃើញពីអរិយធម៌អាស៊ីអាគ្នេយ៍ដែនគោក គឺជាចង្កោមនៃជនជាតិផ្សេងៗ ដែលរស់នៅតាមដងទន្លេ បឹង តំបន់ទំនាប តំបន់ខ្ពង់រាប តំបន់ព្រៃភ្នំ និងតាមតំបន់ដីសណ្តនានា។

តាមរយៈពិព័រណ៍ សំណល់បុរាណវត្ថុ និងកំណត់ត្រាប្រវត្តិសាស្ត្រនៅក្នុងសារមន្ទីរនេះ សុទ្ធតែភស្តុតាងបញ្ជាក់ថា ប្រវត្តិសាស្ត្រដំបូងនៃអ្នករស់នៅតំបន់នេះ គឺមានតាំងពីរដើមគ្រិស្តសករាជមកម្លេះ។ បុរាណវត្ថុ វប្បធម៌ ទំនៀមទម្លាប់ប្រពៃណីរបស់ជនជាតិដើមក្នុងតំបន់ សត្វនិងរុក្ខជាតិនៅក្នុងតំបន់ ទាំងអស់នេះបាននាំឱ្យយើងយល់អំពីប្រវត្តិសាស្ត្រ និងដំណើរនៃវប្បធម៌ដ៏ស្មុកស្មាញដែលបង្ហាញឱ្យឃើញថា តំបន់នេះមានលក្ខណៈពិសេសរបស់ខ្លួនក្នុងប្រវត្តិសាស្ត្រពិភពលោក៕